## ឧបសម្ព័ន្ធទី ១ ការចូលរៀនប្រកបដោយសមធម៌ : ម៉ាទ្រិកផែនការសកម្មភាពគោលនយោបាយទូទៅរបស់វិស័យអប់រំ

| វិសាលភាពគោលនយោបាយ និង យុទ្ធសាស្ត្រ | សកម្មភាព (នៅឆ្នាំ ២០០៦) | សកម្មភាព (នៅឆ្នាំ ២០០៨) | សកម្មភាព (នៅឆ្នាំ ២០១០) |
|---|---|---|---|
| ពង្រីកការចូលរៀនដោយសមធម៌សម្រាប់កុមារអាយុ ៥ ឆ្នាំ ដោយផ្តោតទៅលើឃុំ-សង្កាត់ដែលមានអត្រាចូលរៀនទាប និងអត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា ។<br>ធានាការចូលរៀនរបស់កុមារអាយុ ៦ ឆ្នាំនៅបឋមសិក្សា ដោយធ្វើជំរឿនប្រជាជនជាទៀងទាត់ និងដាក់ចេញក្រឹត្យ និង សេចក្តីណែនាំស្តីពីកុមារអាយុ ៦ ឆ្នាំត្រូវចូលរៀននៅបឋមសិក្សា ។ | • ចេញក្រឹត្យ និងសេចក្តីណែនាំសម្រាប់កុមារអាយុ ៦ ឆ្នាំ ចូលរៀននៅបឋមសិក្សា ដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការអប់រំកុមារតូចអាយុ ៥ ឆ្នាំ ។ | • ពិនិត្យឡើងវិញពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្រការអប់រំកុមារតូច ។ | • ធ្វើអង្កេតពីផលប៉ះពាល់ និងការអនុវត្តតាមក្រឹត្យថ្មីនៃយុទ្ធសាស្ត្រអប់រំកុមារតូច ។ |
| កាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្ស (ដូចជា ចំណាយមិនផ្លូវការ) តាមរយៈការបង្កើនថវិកាសម្រាប់ដំណើរការសាលារៀន និងប្រាក់ខែរបស់គ្រូបង្រៀន ។ | | • លុបបំបាត់ការចំណាយមិនផ្លូវការនៅថ្នាក់ទី ១-៩ នៅទូទាំងប្រទេស ត្រឹមឆ្នាំ ២០០៨ ។<br>• ដាក់ចេញលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការគ្រប់គ្រង និងកិច្ចបញ្ជិការគណនេយ្យនៃប្រាក់វិភាគទានពីមាតាបិតា ត្រឹមឆ្នាំ ២០០៨ ។ | • ពិនិត្យឡើងវិញថវិកាសម្រាប់បឋមសិក្សា និង មធ្យមសិក្សា ឆ្នាំ ២០០៦ - ២០១០ ។ |
| កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅគ្រប់កំរិត ដោយផ្តល់អាទិភាពលើការកែលំអពីថ្នាក់ទី ១-៦ និង កម្មវិធីកាន់តែពាក់ព័ន្ធ ពង្រីកការបំប៉នសិស្សខ្សោយអោយកាន់តែមានប្រសិទ្ធភាពនៅក្នុងឆ្នាំសិក្សាជាមួយនឹងការវាយតម្លៃសិស្សតាមដំណាក់កាល និង ជាប្រចាំ និងការពិនិត្យតាមដានស្តង់ដា ។ | • ដាក់ចេញសេចក្តីណែនាំ និងផែនការសកម្មភាពសម្រាប់ការចូលរៀនឡើងវិញរបស់សិស្សបោះបង់ការសិក្សាពីថ្នាក់ទី ៣-៩ ។ | • ពិនិត្យឡើងវិញការរីកចំរើននៃកម្មវិធីចូលរៀនឡើងវិញ ពីថ្នាក់ទី ៣-៩ ។ | • សិក្សាផលប៉ះពាល់នៃកម្មវិធីចូលរៀនឡើងវិញ និងផលពាក់ព័ន្ធសម្រាប់ពង្រីកនិងកំនត់មុខសញ្ញានាពេលអនាគត ។ |
| អោយមានការចូលពាក់ព័ន្ធកាន់តែច្រើនឡើងពីសំណាក់សហគមន៍/ | | • សិក្សាពីការចូលរួមរបស់ក្រុមប្រឹក្សាឃុំ- | |

| | | | |
|---|---|---|---|
| ឯកជននៅគ្រប់កំរិតសិក្សា ដើម្បីបង្កើនការយល់ដឹងពីសារៈសំខាន់នៃការអប់រំ ព្រមទាំងបង្កើនតម្លាភាព និង គណនេយ្យភាពនៅក្នុងរចនាសម្ព័ន្ធ ។ | | សង្កាត់ និងសមាគមន៍មាតាបិតាសិស្ស នៅក្នុងសកម្មភាពរបស់សាលារៀន ។ | |
| បន្តសាងសង់សាលារៀនថ្មី ឬផ្តល់សម្ភារូបវ័ន្តបន្ថែមដល់សាលាបឋមសិក្សាមិនគ្រប់កំរិតថ្នាក់ ព្រមទាំងផ្តល់អាគារសិក្សាអោយនៅជិតផ្ទះ ដើម្បីកាត់បន្ថយចំណាយផ្ទាល់ និងចំណាយឱកាសដល់គ្រួសារសិស្ស។ | • រៀបចំផែនការអភិវឌ្ឍសម្ភាររូបវ័ន្តសម្រាប់សាលាបឋមសិក្សា រួមទាំងសាលារៀនមិនគ្រប់កំរិតថ្នាក់ ។ | • ពិនិត្យឡើងវិញភាពគ្របដណ្តប់នៃសម្ភាររូបវ័ន្ត ។ | • សិក្សាពីផលប៉ះពាល់នៃប្រសិទ្ធភាពការអភិវឌ្ឍសម្ភាររូបវ័ន្ត ។ |
| បង្កើនការចូលរៀនរបស់សិស្សថ្នាក់ទី ៧-៩ តាមរយៈការសាងសង់សាលារៀនមធ្យមសិក្សាបឋមភូមិនៅក្នុងតំបន់ទទួលសេវាមិនគ្រប់គ្រាន់ ។ | • ផែនការអភិវឌ្ឍន៍សម្ភាររូបវ័ន្តសម្រាប់ថ្នាក់ ទី ៧-៩ ។ | • ពិនិត្យឡើងវិញការរីកចម្រើននៃការពង្រីកថ្នាក់ទី ៧-៩ រួមទាំងការពិនិត្យឡើងវិញ លើលក្ខណៈវិនិច្ឆ័យនៃការសាងសង់ ។ | • ពិនិត្យឡើងវិញផលប៉ះពាល់នៃការពង្រីកថ្នាក់ទី ៧-៩ ។ |
| បង្កើនចំនួនសិស្សចូលរៀននៅថ្នាក់ទី ១០-១២ តាមរយៈការសាងសង់វិទ្យាល័យថ្មីនៅតំបន់ដែលពុំទាន់មាន ។ | • ផែនការអភិវឌ្ឍន៍សម្ភាររូបវ័ន្តសម្រាប់ថ្នាក់ទី ១០-១២ ។ | • ពិនិត្យឡើងវិញការរីកចម្រើននៃការពង្រីកថ្នាក់ទី ១០-១២ រួមទាំងការពិនិត្យឡើងវិញលើលក្ខណៈវិនិច្ឆ័យនៃការសាងសង់ ។ | • ពិនិត្យឡើងវិញផលប៉ះពាល់នៃការពង្រីកថ្នាក់ទី ១០-១២ |
| ធានាការផ្តល់គ្រូបង្រៀននៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ដោយជ្រើសរើសគរុនិស្សិតពីតំបន់ទាំងនោះ តាមរយៈលក្ខណៈវិនិច្ឆ័យជ្រើសរើសដោយឡែក និងជ្រើសរើសគ្រូដែលបានបណ្តុះបណ្តាលដោយ NGOs អោយទៅជាគ្រូមានក្របខណ្ឌស្ថវិការ ។<br>កែលំអប្រសិទ្ធភាពនៃការពង្រាយបុគ្គលិក ដោយផ្តល់រង្វាន់លើកទឹកចិត្តបន្ថែមទៀតដល់គ្រូដែលបង្រៀននៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល ឬតំបន់ជនជាតិភាគតិច ។ | • ផែនការសកម្មភាពសម្រាប់អនុវត្តការបង្រៀនថ្នាក់គួប និងយុទ្ធសាស្ត្រផ្សេងៗទៀតសម្រាប់តំបន់ជាប់ព្រំដែន តំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគតិច ។<br>• ផែនការសកម្មភាពសម្រាប់ការពង្រាយ និងការពង្រាយឡើងវិញ រួមបញ្ចូលទាំងការផ្តល់រង្វាន់លើកទឹកចិត្តសមស្របដល់បុគ្គលិកបង្រៀន និងមិនបង្រៀនដល់សាលារៀនថ្មីៗដែលខ្វះបុគ្គលិក និងការចាប់ផ្តើមអនុវត្តការបណ្តុះបណ្តាលគ្រូ ។ | • ពិនិត្យឡើងវិញការរីកចម្រើនយុទ្ធសាស្ត្រពង្រាយបុគ្គលិកក្នុងឆ្នាំ ២០០៨ ។ | |

| | | | |
|---|---|---|---|
| ធានាផ្តល់ការអប់រំប្រកបដោយគុណភាពនៅមធ្យមសិក្សាទុតិយភូមិ ផ្អែកលើសិស្សពូកែ និងលទ្ធផលនៃការប្រលងថ្នាក់ជាតិថ្នាក់ទី ៩ ។ | | | • ការពិនិត្យឡើងវិញពីផលប៉ះពាល់នៃការចូលរៀនក្រោយមធ្យមសិក្សា ។ |
| បង្កើនចំនួនអាហារូបករណ៍សម្រាប់យុវជនមកពីគ្រួសារក្រីក្រ ពិសេសកុមារី ដើម្បីធានាលទ្ធភាពចូលរៀននៅបឋមសិក្សាមធ្យមសិក្សា និងក្រោយមធ្យមសិក្សា និងការចាប់ផ្តើមអនុវត្តកម្មវិធីគាំទ្រសិស្សពូកែសម្រាប់សិស្សក្រោយកំរិតអប់រំមូលដ្ឋាន មកពីគ្រួសារក្រីក្រ កុមារី និងក្រុមជនជាតិភាគតិច និងក្រុមជនជួបការលំបាកផ្សេងៗ ។ ធានាកំណត់អោយបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រសម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និង កម្មវិធីលើកទឹកចិត្តសម្រាប់សិស្សថ្នាក់ទី ៧-៩ ។ | • ការឯកភាពរបស់ MoEYS/MoEF ស្តីពីការចូលរួមវិភាគទាននៃរដ្ឋាភិបាលសម្រាប់ថ្នាក់ទី ១-១២ ។<br>• របាយការណ៍ស្តីពីចំនួនថវិកាដែលបានផ្តល់ដល់គ្រឹះស្ថានឧត្តមសិក្សា និងចំនួននិស្សិតឧត្តមសិក្សាមិនបង់ថ្លៃ ។ | • ការពង្រីកកម្មវិធីសម្រាប់សិស្សមធ្យមសិក្សា និង ក្រោយមធ្យមសិក្សា ។ | • ការសិក្សាពីផលប៉ះពាល់របស់កម្មវិធីចូលរៀនរបស់និស្សិតតាមសន្ទស្សន៍នៃភាពក្រីក្រ/យេនឌ័រ ។ |
| ពង្រីកការផ្តល់ការអប់រំឧត្តមសិក្សាប្រកបដោយគុណភាព និង សមធម៌ តាមរយៈការលើកកំពស់ភាពជាដៃគូ រវាងសាធារណៈ និង ឯកជន តាមរយៈកំណែទម្រង់ហិរញ្ញវត្ថុ និងគ្រឹះស្ថានសិក្សា ដែលបង្កអោយកាន់តែមានស្វ័យភាពប្រត្តិបត្តិ និងសិទ្ធិបង្កើតប្រាក់ចំណូលសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ។ | | • ផែនការសម្រាប់ពង្រីកគ្រឹះស្ថានឧត្តមសិក្សាតាមដំណាក់កាល ។<br>• ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ទៅជាគ្រឹះស្ថានរដ្ឋបាលសាធាណៈនៅឆ្នាំ ២០០៨ ។ | • សិក្សាពីផលប៉ះពាល់នៃកម្មវិធីពង្រីកគ្រឹះស្ថានឧត្តមសិក្សារួមទាំងការពង្រីកគ្រឹះស្ថានឧត្តមសិក្សានៅតាមបណ្តាខេត្ត-ក្រុង ។ |
| ការពង្រីកភាពជាដៃគូរវាងសាធារណៈ/អង្គការក្រៅរដ្ឋាភិបាល/សហគមន៍ លើការអប់រំក្រៅប្រព័ន្ធនៅតំបន់ជាប់ព្រំដែន និងតំបន់ដាច់ស្រយាល ព្រមទាំងការបង្កើនការផ្តល់ជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមូលដ្ឋាន/ជំនាញវិជ្ជាជីវៈដែលចាំបាច់ឆ្លើយតបទៅនឹងតម្រូវការសង្គម និងទីផ្សារពលកម្ម ។ | | • ការពិនិត្យឡើងវិញពីការវិវត្តនៃការបណ្តុះបណ្តាលជំនាញដល់យុវជន ។<br>• ការពិនិត្យឡើងវិញពីការវិវត្តនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ | • ការសិក្សាពីផលប៉ះពាល់ទៅលើកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ |